សប្តាហ៍ទី
51

ការស្លាប់របស់លោកស្ទេផាន

លោកស្ទេផានស្រឡាញ់ព្រះយេស៊ូវរហូតដល់ទីបញ្ចប់។ លោកបានសម្លឹងមើលទៅស្ថានសួគ៌ អធិស្ឋានទៅកាន់ព្រះជាម្ចាស់ និងអត់ទោសឱ្យពួកគេ!

លោកស្ទេផានបានប្រកាសប្រាប់មនុស្សម្នាអំពីព្រះយេស៊ូដោយប្រាជ្ញាដែលព្រះជាម្ចាស់បានប្រទានមកលោក។

មនុស្សម្នាបានស្អប់លោកស្ទេផាន ហើយបានគប់លោកនឹងថ្ម ប៉ុន្តែលោកស្ទេផានបានសម្លឹងមើលទៅស្ថានសួគ៌ ហើយអធិស្ឋាន។

លោកបានអធិស្ឋានថា៖ «ព្រះអម្ចាស់យេស៊ូអើយ! សូមទទួលវិញ្ញាណទូលបង្គំផង»។ បន្ទាប់មក លោកក៏បានអធិស្ឋានសុំឱ្យព្រះជាម្ចាស់អត់ទោសឱ្យអ្នកដែលសម្លាប់លោកផងដែរ។

លោកស្ទេផានគឺជាអ្នកបម្រើដ៏ក្លាហានរបស់ព្រះជាម្ចាស់ ដែលបានស្រឡាញ់ព្រះយេស៊ូវរហូតដល់ទីបញ្ចប់។

[កិច្ចការជំពូក៧]

ការធ្វើកាតផ្សាយដំណឹងល្អ








សម្ភារៈ


ក្រដាសស្តើរនៃកាតផ្សាយដំណឹងល្អ


ប៊ិតពណ៌


កន្ត្រៃ


ការ


ស្ទីគ័រ (ជម្រើសបន្ថែម)

របៀបធ្វើសកម្មភាព

1. សរសេរអក្សរ និងគូរូបលើកាត។
2. ជាត់ពណ៌ និងតុបតែងកាតឱ្យបានស្អាត។
3. សរសេរពាក្យដែលចង់ប្រាប់នៅផ្នែកខាងក្រោយនៃកាត។
4. ចោះប្រហោងកាត ហើយចងខ្សែភ្ជាប់។
5. កាតផ្សាយដំណឹងល្អរបស់យើងរួចរាល់ហើយ!



ការពង្រីកសកម្មភាព

- ចែកកាតផ្សាយដំណឹងល្អនេះទៅដល់មិត្តភក្តិ ឬក្រុមគ្រួសារ។
- សាកល្បងតុបតែងដោយប្រើពណ៌ និងស្ទីគ័រចម្រុះ។
- សាកល្បងសរសេរពាក្យពេចន៍ពីរោះៗបន្ថែមទៀត ដែលយើងចង់ប្រាប់ពួកគេ។
- ប្រមូលកាតផ្សាយដំណឹងល្អទាំងអស់ យកទៅដាក់តាំងក្នុងកន្ត្រកដ៏ស្រស់ស្អាតមួយ។

Tip សម្រាប់គ្រូ

- រៀបចំខ្លឹមសារ ឬពាក្យពេចន៍ណាដែលងាយស្រួល ឱ្យកុមារងាយយល់។
- បញ្ជាក់ប្រាប់កុមារថា ការផ្សាយដំណឹងល្អ គឺការចែករំលែកដោយក្តីស្រឡាញ់ចេញពីបេះដូង។
- ណែនាំកុមារ ឱ្យហុចកាតនេះទៅអ្នកដទៃដោយស្នាមញញឹមដ៏ស្រស់ស្រាយ។
- លើកទឹកចិត្តកុមារ ឱ្យតុបតែងកាតដោយខ្លួនឯង ដើម្បីបណ្តុះទំនុកចិត្តដល់ពួកគេ។